**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...០៩...សរ.ណន

# សារាចរណែនាំ

## ស្តីពី

## នីតិវិធីនៃការប្រឡងប្រជែងដើម្បីប្តូរប្រភេទក្របខ័ណ្ឌ របស់មន្ត្រីរាជការស៊ីវិល

កន្លងមក រាជរដ្ឋាភិបាលពិនិត្យឃើញថា ក្រសួង ស្ថាប័នមួយចំនួនពុំទាន់បានអនុវត្តការប្រឡងប្រជែងដើម្បីផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌឱ្យមានការឯកភាពគ្នា ស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃគ្រប់ប្រភេទក្របខ័ណ្ឌមុខងារសាធារណៈ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗទៀតនៅឡើយ។ ដើម្បីលើកទឹកចិត្តដល់មន្ត្រីរាជការដែលមានក្របខ័ណ្ឌទាប និងដែលបានខិតខំបំពេញការងារយ៉ាងសកម្មអស់រយៈពេលជាច្រើនឆ្នាំ និងផ្តល់ឱកាសដល់មន្ត្រីដែលបានខិតខំអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួនដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ ឱ្យមានលទ្ធភាពបានផ្លាស់ប្តូរក្របខ័ណ្ឌទៅកាន់ប្រភេទក្របខ័ណ្ឌមួយទៀតខ្ពស់ជាង និងក្នុងគោលដៅពង្រឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលឱ្យកាន់តែមានប្រសិទ្ធភាពក្នុងក្របខ័ណ្ឌនៃការអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈ និងការពង្រឹងនីតិរដ្ឋនៅក្នុងរដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលសូមធ្វើការណែនាំអំពីនីតិវិធីនៃការប្រឡងប្រជែងផ្ទៃក្នុងមន្ត្រីរាជការរបស់ក្រសួងស្ថាប័នដូចខាងក្រោម៖

### ១- ចំនួនជ្រើសរើស

ចំនួនតំណែងជ្រើសរើស ត្រូវស្របជាមួយចំនួនតំណែងដែលមានទំនេរ។ តំណែងទំនេរគឺជាតំណែងដែលកើតឡើងពីការបង្កើតមុខងារថ្មី ការចូលនិវត្តន៍ ការបោះបង់ចោលការងារ មរណភាព ការសុំលាឈប់ពីការងារ ការលុបឈ្មោះ ការបាត់បង់សមត្ថភាពការងារ និងការផ្ទេរចេញរបស់មន្ត្រីរាជការ ជាដើម។

ចំនួនតំណែងដែលត្រូវធ្វើការប្រឡងប្រជែងផ្ទៃក្នុងដើម្បីប្តូរប្រភេទក្របខ័ណ្ឌ ត្រូវចាត់ទុកជាផ្នែកមួយនៃចំនួនផែនការជ្រើសរើសមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌថ្មីប្រចាំឆ្នាំដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាល។

### ២- លក្ខណសម្បត្តិជ្រើសរើស

ការផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌរបស់មន្ត្រីរាជការស៊ីវិល ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការស៊ីវិលរបស់ក្រសួងស្ថាប័ន តាមលក្ខខណ្ឌដូចខាងក្រោម៖

២.១- ការប្រឡងប្រជែងចូលក្នុងក្របខ័ណ្ឌប្រភេទ **ក៖** មន្ត្រីរាជការស៊ីវិលត្រូវមានសញ្ញាប័ត្រសមមូលនឹងបរិញ្ញាបត្រ ឬមន្ត្រីរាជការស៊ីវិលដែលស្ថិតនៅយ៉ាងទាបបំផុតក្នុងថ្នាក់លេខ១១ ឋានន្តរស័ក្តិទី៣នៃក្របខ័ណ្ឌប្រភេទ **ខ**។

២.២- ការប្រឡងប្រជែងចូលក្នុងក្របខ័ណ្ឌប្រភេទ **ខ៖** មន្ត្រីរាជការស៊ីវិលត្រូវមានសញ្ញាប័ត្រសមមូលនឹងមធ្យមសិក្សាទុតិយភូមិ បូក០២ឆ្នាំសិក្សាដែលមានសញ្ញាបត្រ ឬមន្ត្រីរាជការស៊ីវិលដែលស្ថិតនៅ

យ៉ាងទាបបំផុតក្នុងថ្នាក់លេខ១១ ឋានន្តរស័ក្តិទី៣នៃក្របខ័ណ្ឌប្រភេទ **គ** ។

២.៣- ការប្រឡងប្រជែងចូលក្នុងក្របខ័ណ្ឌប្រភេទ **គ៖** មន្ត្រីរាជការស៊ីវិលត្រូវមានសញ្ញាប័ត្រសមមូលនឹងមធ្យមសិក្សាទុតិយភូមិ ឬមន្ត្រីរាជការស៊ីវិលដែលស្ថិតនៅក្នុងក្របខ័ណ្ឌប្រភេទ **ឃ** ដែលបានបំពេញការងារ ៥ ឆ្នាំពេញលេញយ៉ាងតិចរួចមកហើយ។

២.៤- ចំពោះលក្ខខណ្ឌអាយុ ត្រូវអនុវត្តតាមការកំណត់របស់លក្ខន្តិកៈដោយឡែកនៃប្រភេទក្របខ័ណ្ឌនីមួយៗ លើកលែងតែរាជរដ្ឋាភិបាលមានការកំណត់ផ្សេងក្រៅពីនេះ។

## ៣- វិញ្ញាសានៃការប្រឡងប្រជែង

វិញ្ញាសានៃការប្រឡងប្រជែងដើម្បីប្តូរប្រភេទក្របខ័ណ្ឌ មានពីរផ្នែក៖ វិញ្ញាសាសរសេរ និង វិញ្ញាសាសួរផ្ទាល់មាត់។

វិញ្ញាសាសរសេរ ជាវិញ្ញាសាដែលមានលក្ខណៈឯកទេស ដើម្បីវាស់ស្ទង់លើជំនាញសំខាន់ៗរបស់វិជ្ជាជីវៈ និងមានការពាក់ព័ន្ធទៅនឹងបទពិសោធជាក់ស្តែងក្នុងការអនុវត្តការងារនៃក្របខ័ណ្ឌដែលត្រូវប្រឡងប្តូរ។

វិញ្ញាសាសួរផ្ទាល់មាត់ ត្រូវអនុវត្តចំពោះបេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរ។ វិញ្ញាសានេះគឺជាវិញ្ញាសាវាយតម្លៃនូវគុណភាពនៃបទពិសោធន៍ ជំនាញបណ្តុះបណ្តាលនិងការសិក្សា ចំណេះដឹងឯកទេស និងភាពប៉ិនប្រសប់ដែលវិជ្ជាជីវៈ ឬតំណែងតម្រូវ។

## ៤- គណៈកម្មការប្រឡងប្រជែង

ក្រសួង ស្ថាប័នសាមី ត្រូវរៀបចំ និងគ្រប់គ្រងផ្ទាល់ការប្រឡងប្រជែងដើម្បីប្តូរប្រភេទក្របខ័ណ្ឌ ដោយមានការចូលរួមពីតំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងតំណាងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល។

ដើម្បីធានាឱ្យការប្រឡងប្រជែងប្រព្រឹត្តទៅដោយសុក្រឹត មានការឯកភាពគ្នា ភាពរលូន និងតម្លាភាព ក្រសួងស្ថាប័នត្រូវបង្កើតគណៈកម្មការរៀបចំការប្រឡងតាមគោលការណ៍និងនីតិវិធីនៃការប្រឡងប្រជែង ជាពិសេសត្រូវមាន៖

- គណៈកម្មការរៀបចំការប្រឡង
- គណៈកម្មការចុះលេខសម្ងាត់និងកាត់ក្បាលវិញ្ញាសា
- គណៈកម្មការកំណែ
- គណៈកម្មការសួរផ្ទាល់មាត់ និង
- គណៈកម្មការស្រង់ បូកពិន្ទុ និងសរុបលទ្ធផលនៃការប្រឡងប្រជែង។

សមាសភាពរបស់គណៈកម្មការនីមួយៗ ត្រូវមានតំណាងស្ត្រីរបស់ក្រសួងស្ថាប័នសាមីចូលរួម។

គណៈកម្មការរៀបចំការប្រឡងរបស់ក្រសួងស្ថាប័ន ត្រូវធ្វើរបាយការណ៍ស្តីពីការរៀបចំ និងដំណើរការប្រព្រឹត្តទៅ ព្រមទាំងលទ្ធផលនៃការប្រឡងជូនប្រធានស្ថាប័នជ្រាប និងសម្រេចលើលទ្ធផលចុងក្រោយ។

## ៥- ការផ្តល់ពិន្ទុបន្ថែម និងអាទិភាព

គណៈកម្មការរៀបចំការប្រឡងរបស់ក្រសួងស្ថាប័ននីមួយៗ ត្រូវពិនិត្យនិងពិភាក្សាឱ្យបានហ្មត់ចត់ក្នុងការផ្តល់ពិន្ទុបន្ថែម ឬ ផ្តល់អាទិភាពក្នុងករណីដែលមានពិន្ទុត្រូវគ្នា ទៅលើមុខសញ្ញាដូចខាងក្រោម៖

- បេក្ខជនមន្ត្រីរាជការដែលស្ថិតនៅតំបន់ដាច់ស្រយាល
- បេក្ខជនមន្ត្រីរាជការជាស្ត្រី និងអ្នកដែលមានអាយុច្រើនជាង
- មន្ត្រីដែលមានក្របខ័ណ្ឌទាបជាងមុខតំណែង

- ជនជាតិភាគតិច
- ជនពិការដោយគ្រោះថ្នាក់ការងារ ឬក្នុងការបំពេញបេសកកម្ម។

**៦- កាលបរិច្ឆេទនៃការប្រឡងប្រជែង**

ក្រសួង ស្ថាប័នត្រូវរៀបចំការប្រឡងប្រជែងឲ្យបាននៅក្នុងឆ្នាំដែលរាជរដ្ឋាភិបាលបានអនុញ្ញាតផ្តល់ជូន។ ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៧ ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ